# របាយការណ៍ សិក្ខាសាលានិងមហាសន្និបាត
# អង្គការជនពិការខួរឆ្អឹងខ្នងកម្ពុជា





REPORT ON THE WORKSHOP ON SPINARD CORD SUPPORT

AND 1st GENERAL ASSEMBLY

25 – 26 March 2013

# របាយការណ៍ សិក្ខាសាលានិងមហាសន្និបាត
# អង្គការជនពិការខ្វះឆ្អឹងខ្នងកម្ពុជា

## មាតិកា


**១. សេចក្តីផ្តើម** ........ 2

**២. គោលបំណង** ........ 2

**៣. ដំណើរការនៃសិក្ខាសាលានិងមហាសន្និបាត** ........ 2

៣.១. ចំណាប់អារម្មណ៍របស់តំណាងជនពិការខ្វះឆ្អឹងខ្នង ដែលថ្លែងដោយ កញ្ញា ជាតិ សុខា ........ 3

៣.២. ចំណាប់អារម្មណ៍របស់ លោក ងិន សៅរ័ត្ន នាយកប្រតិបត្តិ អង្គការជនពិការកម្ពុជា ........ 3

៣.៣. ចំណាប់អារម្មណ៍របស់លោក ដុកទ័រ ថូម៉ាសតំណាងអង្គការRESCIO នៃប្រទេស ន័រវេ ........ 4

៣.៤. សុន្ទរកថាបើកដោយ ឯកឧត្តម **រស់ ឡើន** អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា 4

៣.៥. បទបង្ហាញអំពី លទ្ធផល នៃ ការស្រាវជ្រាវលើជនពិការខ្វះ ឆ្អឹងខ្នង ........ 5

៣.៦. បទបង្ហាញស្តីពី សមាគមជនពិការខ្វះឆ្អឹងខ្នងន័រវេ ........ 6

៣.៧. កិច្ចពិភាក្សាក្រុម ........ 7

៣.៨. សកម្មភាពកីឡា ........ 11

៣.៩. ចំណាប់អារម្មណ៍បើក ដោយលោក ងិន សៅរ័ត្ន នាយកប្រតិបត្តិ អង្គការជនពិការកម្ពុជា ........ 12

៣.១០. ដំណើរការ និង នីតិវិធីនៃការជ្រើសរើស ក្រុមប្រឹក្សាភិបាល ........ 12

៣.១១. លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាភិបាល ........ 13

៣.១២. បោះឆ្នោតជ្រើសរើស តួនាទីក្រុមប្រឹក្សាភិបាល ប្រធាន អនុប្រធាន ហេរញ្ញិក និង នាយកប្រតិបត្តិ ........ 15

៣.១៣. តួនាទីរបស់ ក្រុមប្រឹក្សាភិបាល ........ 15

# របាយការណ៍ សិក្ខាសាលានិងមហាសន្និបាត
# អង្គការជនពិការខ្វះឆ្អឹងខ្នងកម្ពុជា

## ១. សេចក្តីផ្តើម

អង្គការជនពិការខ្វះឆ្អឹងខ្នងកម្ពុជា ខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលាមួយស្តីពីការគាំទ្រជនពិការខ្វះឆ្អឹងខ្នង  និងមហាសន្និបាតលើកទី១ នៅមណ្ឌលស្តារលទ្ធភាពពលកម្មអ្នករបួសខ្វះឆ្អឹងខ្នងខេត្តបាត់ដំបង។ សិក្ខាសាលានិង មហាសន្និបាតលើកទី១នេះត្រូវបានការចូលរួមដ៏ខ្ពង់ខ្ពស់ ពីសំណាក់ ឯកឧត្តម **រស់ រឿន** អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

សិក្ខាសាលានិង មហាសន្និបាតនេះក៏បានការចូលរួមពីសំណាក់ជនពិការ និងអ្នករបួសខ្វះឆ្អឹងខ្នងចំនួន ៤៣នាក់។

## ២. គោលបំណង

គោលបំណងនៃ សិក្ខាសាលានិង មហាសន្និបាតគឺ៖

- បង្កើនការផ្សព្វផ្សាយ និងយល់ដឹងអំពីជនពិការខ្វះឆ្អឹងខ្នង
- បង្កើតក្រុមប្រឹក្សាភិបាលសម្រាប់អង្គការជនពិការខ្វះឆ្អឹងខ្នង

## ៣. ដំណើរការនៃសិក្ខាសាលានិងមហាសន្និបាត

**ថ្ងៃទី១៖ ២៥ ខែមីនា ២០១៣៖**

**សិក្ខាសាលាស្តីអំពីការគាំទ្រជនពិការខ្វះឆ្អឹងខ្នង**

ជាកម្មវិធីបើកសិក្ខាសាលាស្តីអំពីការគាំទ្រជនពិការខ្វះឆ្អឹងខ្នង និងមហាសន្និបាតលើកទី១ ដែលមានឯកឧត្តម **រស់ រឿន** អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចូលរួមជាគណៈអធិបតី ភ្ញៀវកិត្តិយសមួយចំនួនដូចជា លោក ងិន សៅរ័ត្ន នាយកប្រតិបត្តិ អង្គការជនពិការកម្ពុជា លោក គឹម តេង ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ខេត្ត បាត់ដំបង លោក ដុកទ័រ ថូម៉ាស លោក រ៉ូន និលសិន ព្រមទាំងជនពិការខ្វះឆ្អឹងខ្នងមួយចំនួន៤៣នាក់។ ក្នុងនោះមានការថ្លែងចំណាប់អារម្មណ៍ក្នុងកម្មវិធីបើកសិក្ខាសាលា និងមហាសន្និបាតមានដូចជា៖

### ៣.១. ចំណាប់អារម្មណ៍របស់តំណាងជនពិការខួរឆ្អឹងខ្នង ដែលថ្លែងដោយ កញ្ញា ជាតិ សុខា




កញ្ញា ជាតិ សុខា បានមានចំណាប់អារម្មណ៍ថា ការបើកនូវសិក្ខាសាលា និង មហាសន្និបាតលើកទី១ របស់ ជនពិការខួរឆ្អឹងខ្នងនេះពិតជាមានសារសំខាន់ណាស់ក្នុងការត្រួសត្រាយផ្លូវ ទៅកាន់ការបំពេញនូវតំរូវការ ជាក់ស្តែង និងពិតប្រាកដរបស់ជនពិការខួរឆ្អឹងខ្នង។

### ៣.២. ចំណាប់អារម្មរណ៍របស់ លោក ងិន សៅរ័ត្ន នាយកប្រតិបត្តិ អង្គការជនពិការកម្ពុជា



លោក ងិន សៅរ័ត្ន បានមានថ្លែងនូវចំណាប់អារម្មណ៍ចំពោះបងប្អូនជនពិការខួរឆ្អឹងខ្នង នៅក្នុងសិក្ខាសាលា និងមហាសន្និបាតនេះថា៖ « ប្រទេសកម្ពុជាមានជនពិការរាប់ម៉ឺននាក់។ ជាពិសេសជនពិការខួរឆ្អឹងខ្នងភាគច្រើនមានជីវភាពរស់នៅយ៉ាងលំបាកវេនា ដោយសារភាពក្រីក្រ។ ជនពិការខួរឆ្អឹងខ្នងពិការក្នុងការស្វែងរកការងារធ្វើ សេវាថែទាំសុខភាព និង មានចំណេះដឹងមានកំរិតទាប។ ខ្ញុំជឿជាក់ថា ការបង្កើតអង្គការតំណាងជនពិការខួរឆ្អឹងខ្នងនេះនឹងជួយដល់ជនពិការខួរឆ្អឹងខ្នង ក្នុងប្រទេសកម្ពុជាយើងនាពេលអនាគត។»

### ៣.៣. ចំណាប់អារម្មណ៍របស់លោក ដុកទ័រ ថូម៉ាសតំណាងអង្គការRESCIO នៃប្រទេស ន័រវេ

លោក ដុកទ័រ ថូម៉ាស គ្លូត  បានមានប្រសាសន៍ថា សិក្ខាសាលានេះមានសារសំខាន់សម្រាប់ជនពិការខួរឆ្អឹងខ្នងនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីពេលនេះតទៅ ជនពិការខួរឆ្អឹងខ្នង មានតំណាងរបស់ខ្លួន ក្នុងការជួយសម្របសម្រួលនូវសេវាកម្មនានាដល់បងប្អូនជនពិការខួរឆ្អឹងខ្នង។



### ៣.៤. សុន្ទរកថាបើកដោយ ឯកឧត្តម **រស់ រឿន** អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា




ឯកឧត្តម រស់ រឿន អនុរដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានមានថ្លែងនូវសុន្ទរកថាបើកនូវសិក្ខាសាលា និងមហាសន្និបាតជនពិការខួរឆ្អឹងខ្នងនេះថា៖

« បងប្អូនជនពិការខួរឆ្អឹងខ្នង ក៏ដូចជាជនពិការទូទៅដ៏ទៃទៀតដែរ បងប្អូនត្រូវការការពារសិទ្ធិការ ទទួលបាននូវសេវាសង្គមនានាដូចជា សេវាព្យាបាលដោយឥតគិតថ្លៃ សេវាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការចូលរួមក្នុងសហគមន៍ដោយគ្មានការរើសអើង និងជាពិសេសគឺឱកាសទទួលបានការងារសមរម្យ ដើម្បី ទ្រទ្រង់កំរិតជីវភាពក្នុងគ្រួសាររបស់បងប្អូនពិការយើង។ ឆ្លើយតបទៅនឹង តំរូវការនេះ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍនានានិងអង្គការតំណាងជនពិការនានា បានជំរុញនូវការ

កសាងសមត្ថភាព បណ្តុះបណ្តាលវិជ្ជាជីវៈ មុខជំនាញការងារ មុខរបរដល់ជនពិការ ដើម្បីធានានូវនិរន្តរភាពកំរិតជីវភាពដល់បងប្អូនជនពិការយើង។ ទន្ទឹមនឹងនោះដែរ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ទទួលបាននូវការគាំទ្រ និងគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាលស្តីពី ការអនុវត្តអត្រាជនពិការ ចូលបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋ ដែលចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ វិស័យសាធារណ ចំនួន ២% និងវិស័យឯកជន ១%។

បន្ទាប់ពីសុន្ទរកថាបើក របស់ **ឯកឧត្តម រស់ រឿន** អនុរដ្ឋលេខាធិការ គឺមានពិធីថតរូបជុំគ្នាទុកជាអនុស្សាវរីយជាមួយបងប្អូនជនពិការខួរឆ្អឹងខ្នង និងការនិវត្តវិញរបស់គណអធិបតី។



### ៣.៥. បទបង្ហាញអំពី លទ្ធផល នៃ ការស្រាវជ្រាវលើជនពិការខួរ ឆ្អឹងខ្នង

បន្ទាប់ពីការនិវត្តវិញរបស់គណអធិបតី លោក ដុកទ័រ ថូម៉ាស បានធ្វើបទបង្ហាញអំពី លទ្ធផល នៃ ការស្រាវជ្រាវលើជនពិការខួរ ឆ្អឹងខ្នង ជូនដល់អ្នកចូលរួមបានជ្រាប។



## ៣.៦. បទបង្ហាញស្តីពី សមាគមជនពិការខួរឆ្អឹងខ្នងន័រវេ



លោក អាន អូឡាវ ហូប តំណាងសមាគមអ្នករបួសខួរឆ្អឹងខ្នងន័រវេបានធ្វើបទបង្ហាញ អំពីជនពិការខួរឆ្អឹងខ្នងនៅប្រទេសន័រវេដើម្បីចែករំលែក នូវចំណេះដឹង បទពិសោធន៍នានាទាក់ទងនឹងជនពិការខួរឆ្អឹងខ្នងក្នុង ប្រទេសន័រវេនៅក្នុងសិក្ខាសាលា។

## ៣.៧. កិច្ចពិភាក្សាក្រុម

អ្នកចូលរួមត្រូវបានបំបែកជា ៥ក្រុម ដើម្បីធ្វើការពិភាក្សាលើប្រធានបទចំនួន ៥ ដូចខាងក្រោមនេះ៖



ក្រុម១៖ តើខ្ញុំអាចកែប្រែការរស់នៅរបស់ ខ្ញុំ ដោយរបៀបណាក្នុងនាមខ្ញុំជាជនពិការខួរឆ្អឹងខ្នង?



ក្រុម២៖ តើឧបសគ្គចំបងអ្វីខ្លះ ដែលជនពិការខួរឆ្អឹងខ្នង បាននឹងកំពុងជួបប្រទះ?



ក្រុម៣៖ តើយើងត្រូវដោះស្រាយឧបសគ្គនោះយ៉ាងដូចម្តេច?



ក្រុម៤៖ តើគួរបង្កើតអង្គការជនពិការខួរឆ្អឹងខ្នងឬទេ? បើបង្កើត តើគួរធ្វើដូចម្តេច?



ក្រុម៥៖ តើជំនាញ និងបច្ចេកទេសអ្វីខ្លះដែលអ្នកត្រូវការ?

បន្ទាប់ពីបានធ្វើការពិភាក្សាលើប្រធានបទទាំង៥ ក្រុមពិភាក្សាបានធ្វើបទបង្ហាញនូវលទ្ធផលនៃការពិភាក្សាមានដូចខាងក្រោមនេះ៖

| | |
|---|---|
| ក្រុមទី១៖<br>ប្រធានបទ៖ តើខ្ញុំអាចកែប្រែការរស់នៅរបស់ខ្ញុំ ដោយរបៀបណាក្នុងនាមខ្ញុំជាជនពិការខួរឆ្អឹងខ្នង? | លទ្ធផល៖<br>ការពិភាក្សារបស់ក្រុមមាន ក្នុងនាមខ្ញុំជាជនពិការខួរឆ្អឹងខ្នង ខ្ញុំកែប្រែការរស់នៅរបស់ខ្ញុំដូចជា៖<br>- ព្រមទទួលយកពិការភាពដើម្បីអាចចូលរួមក្នុងសកម្មភាពនានារបស់សង្គម<br>- មានទំនាក់ទំនងល្អជាមួយសង្គមខាងក្រៅ<br>- ស្វែងរកជំនាញមួយជាក់លាក់ដើម្បីជាអាជីពសំរាប់ជីវិតក្នុងការរស់នៅ<br>- ត្រូវរក្សាសុខភាពអោយបានល្អដោយបរិភោគអាហារណាដែលមានជីវជាតិ អោយបានគ្រប់គ្រាន់និងមានអនាម័យល្អក្នុងការរស់នៅ<br>- គេងអោយបានគ្រប់គ្រាន់<br>- ប្រុងប្រយត្ន័កុំអោយមានដំបៅកើតឡើង<br>- តស៊ូព្យាយាមជំនះគ្រប់ឧបសគ្គ ដែលកើតមានក្នុងពេលបច្ចុប្បន្ន និង អនាគតកាល ។ |



ក្រុមទី២៖

ប្រធានបទ៖ តើឧបសគ្គចំបងអ្វីខ្លះ ដែលជនពិការខួរឆ្អឹងខ្នង បាននឹងកំពុងជួបប្រទះ?



លទ្ធផល៖

ឧបសគ្គដែលជនពិការខួរឆ្អឹងខ្នងជួបប្រទះមានដូចជា៖

- ការរើសអើងពីសំណាក់អ្នកជិតខាង ពីសង្គម និងក្រុមគ្រួសារ
- បាត់បង់ការសិក្សា
- បញ្ហាសុខភាព
- ការធ្វើដំណើរសំណង់ខ្លះគ្មានជំរាល
- ពិបាក់ក្នុងការចូលរួមរកការងារធ្វើ ប្រកបមុខរបរ
- បញ្ហាក្នុងការរស់នៅ
- បញ្ហាផ្លូវចិត្ត

ក្រុមទី៣៖

ប្រធានបទ៖ តើយើងត្រូវដោះស្រាយឧបសគ្គនោះយ៉ាងដូចម្តេច?



លទ្ធផល៖

- ពិបាកក្នុងការធ្វើដំណើរតាមផ្លូវ ពិបាកក្នុងការឈឺចាប់ក្នុងខ្លួន
- ពិបាកអត់ការងារធ្វើ ហើយការងារមានការរើសអើងខាងពិការខួរឆ្អឹងខ្នង
- ខ្វះឧបករណ៍ប្រើប្រាស់មួយចំនួន( គ្មានបន្ទប់ទឹក បង្គន់ប្រើប្រាស់ក្នុងគ្រួសារ)
- ខ្វះខាតមុខជំនាញ ខ្លះៗ ក្នុងការរស់នៅ
- ខ្វះការគាំទ្រពីក្រុមគ្រួសារ
- បញ្ហាសេវាកម្មសាធារណៈ
- បញ្ហាសុខភាព
- បញ្ហាឧបករណ៍ប្រើប្រាស់ ( រទេះ ពូក ។ល។ )

ក្រុមទី៤៖
ប្រធានបទ៖ តើគួរបង្កើតអង្គការជនពិការខួរឆ្អឹងខ្នង ឬទេ? បើបង្កើត តើគួរធ្វើដូចម្តេច?



លទ្ធផល៖

- ត្រូវបង្កើតអង្គការជនពិការខួរឆ្អឹងខ្នង
- ធ្វើការប្រមូលផ្តុំជនពិការបង្កើតជាសហគមន៍សិក្សាស្វែងយល់ពីទុក្ខលំបាករបស់ជនពិការ
- ទំនាក់ទំនងជនពិការខួរឆ្អឹងខ្នងតាមសហគមន៍និងអង្គការ
- ត្រូវតែស្វែងយល់សិក្សាអំពីបញ្ហាការរស់នៅរបស់ជនពិការនិងតំរូវការរបស់ពួកគេ
- រៀបចំធ្វើរបាយការណ៏និងគំរោងផ្សេងៗ
- ស្វែងរកការគាំទ្រនិងសហការណ៏ពីរដ្ឋាភិបាលអង្គការជាតិនិង អន្តរជាតិ
- ស្វែងរកម្ចាស់ជំនួយដើម្បីមានលទ្ធភាពទ្រទ្រង់អង្គការនេះឡើង

ក្រុមទី៥៖
ប្រធានបទ៖ តើជំនាញ និងបច្ចេកទេសអ្វីខ្លះដែលអ្នកត្រូវការ?



លទ្ធផល៖

- ជួសជុលទូរសព្ទ័ ម៉ាញេ និង ទូរទស្សន៍
- កាត់ដេរ
- កីឡា
- លក់ដូរ
- ចិញ្ចឹមសត្វ
- សិល្បៈនិងឧបករណ៏តន្ត្រី
- ជំនាញកុំព្យូទ័រ

## ៣.៨. សកម្មភាពកីឡា

អ្នកចូលរួមបាននាំគ្នាលេងកីឡាបាល់បោះទាំងអស់គ្នា ដើម្បីផ្សារភ្ជាប់កីឡា និងសុខភាព។





**ថ្ងៃទី២៖២៦ មីនា ២០១៣**
**មហាសន្និបាតជ្រើសរើសក្រុមប្រឹក្សាភិបាល អង្គការជនពិការខួរឆ្អឹងខ្នង**

### ៣.៩. ចំណាប់អារម្មណ៍បើក ដោយលោក ងិន សៅរ័ត្ន នាយកប្រតិបត្តិ អង្គការជនពិការកម្ពុជា

លោក ងិន សៅរ័ត្ន បានបង្ហាញ ចំណាប់អារម្មណ៍ថាការជ្រើសរើស ក្រុមប្រឹក្សាភិបាល នៃអង្គការជនពិការខួរឆ្អឹងខ្នងគឺមានសារសំខាន់ណាស់។ ក្រុមប្រឹក្សាភិបាលជាអ្នក ផ្តល់នូវភាពដឹកនាំដល់ ថ្នាក់ដឹកនាំរបស់អង្គការ ដើម្បីធានាថាអង្គការជនពិការខួរឆ្អឹងខ្នង មិនមានអំពើពុករលួយ មានតម្លាភាព និងភាពទទួលខុសត្រូវខ្ពស់នៅចំពោះមុខជនពិការទាំងអស់។



### ៣.១០. ដំណើរការ និង នីតិវិធីនៃការជ្រើសរើស ក្រុមប្រឹក្សាភិបាល

លោក គី សុផាន់ ប្រធានគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ អង្គការជនពិការកម្ពុជា បានធ្វើការពន្យល់ពី នីតិវិធីនៅក្នុងការគូសសន្លឹកឆ្នោត និងបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សាភិបាល។ សន្លឹកឆ្នោតដែលមិនមានគោរពតាមលក្ខខ័ណ្ឌត្រូវចាត់ទុកជាមោឃៈ។



## ៣.១១. លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាភិបាល

ក្នុងចំណោមអ្នកចូលរួមទាំងអស់ មានអ្នកមានសិទ្ធិបោះឆ្នោតមានចំនួន ៣៨នាក់។ បេក្ខជនឈរឈ្មោះបោះឆ្នោតមានចំនួន ១២ នាក់ ក្នុងនោះមានស្ត្រីចំនួន ៤ នាក់ ។



លទ្ធផលនៃការបោះឆ្នោតមានដូចតទៅនេះ៖

| ល.រ | ឈ្មោះបេក្ខជន | ឈ្មោះបេក្ខជន (អង់គ្លេស) | ភេទ | ចំនួនសន្លឹកឆ្នោតទទួលបាន |
|---|---|---|---|---|
| ១ | យី ណារីន | Yi Narin | ប្រុស | ៨ |
| ២ | សួង សុវណ្ណារ័ត្ន | Suong Sovannaroath | ប្រុស | ១៨ |
| ៣ | ជា ណាន់ | Chea Nan | ប្រុស | ២១ |
| ៤ | ចន្នី ដាវី | Channy Davy | ស្រី | ១៥ |
| ៥ | ជៀច ចាន់ | Cheach Chan | ប្រុស | ៩ |
| ៦ | ឃួន សុខា | Khuon Sokha | ប្រុស | ៥ |
| ៧ | ង៉ូវ ច្រិប | Ngouv Chrib | ស្រី | ៩ |
| ៨ | ហាក់ សំណាង | Hak Samnang | ប្រុស | ២១ |
| ៩ | យ៉ែម ភារុណ | Yem Phearun | ប្រុស | ២២ |
| ១០ | ឆើត សុធារី | Chheut Sotheary | ស្រី | ១០ |
| ១១ | សៀង សុខចាន់ | Seang Sok Chan | ស្រី | ២០ |
| ១២ | យិន នាងស៊ីណាត | Yin Neang Sinat | ប្រុស | ២៧ |

បេក្ខជនដែលជាប់ជា ក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម៖

| ល.រ | នាមក្រុមប្រឹក្សាភិបាល | នាមក្រុមប្រឹក្សាភិបាល (អង់គ្លេស) | ភេទ | ចំនួនសន្លឹកឆ្នោតទទួលបាន |
|---|---|---|---|---|
| ១ | យិន នាងស៊ីណាត | Yin Neang Sinat | ប្រុស | ២៧ |
| ២ | យ៉ែម ភារុណ | Yem Phearun | ប្រុស | ២២ |
| ៣ | ហាក់ សំណាង | Hak Samnang | ប្រុស | ២១ |
| ៤ | ជា ណាន់ | Chea Nan | ប្រុស | ២១ |
| ៥ | សៀង សុខចាន់ | Seang Sok Chan | ស្រី | ២០ |
| ៦ | សួង សុវណ្ណារ័ត្ន | Suong Sovannaroath | ប្រុស | ១៨ |
| ៧ | ចន្នី ដាវី | Channy Davy | ស្រី | ១៥ |



## ៣.១២. បោះឆ្នោតជ្រើសរើស តួនាទីក្រុមប្រឹក្សាភិបាល ប្រធាន អនុប្រធាន ហេរញ្ញិក និង នាយកប្រតិបត្តិ

បន្ទាប់ពីជាប់ជាសមាជិក សមាជិកា ក្រុមប្រឹក្សាភិបាល គឺមានការបោះឆ្នោតជ្រើសរើស នូវតួនាទី ប្រធាន អនុប្រធាន និងហិរញ្ញិក។ លទ្ធផលនៃការបោះឆ្នោតទទួលបានដូចខាងក្រោមនេះ៖

| ល.រ | នាមក្រុមប្រឹក្សាភិបាល | នាមក្រុមប្រឹក្សាភិបាល (អង់គ្លេស) | ភេទ | តួនាទី | ចំនួនសន្លឹកឆ្នោតទទួលបាន |
|---|---|---|---|---|---|
| ១ | យិន នាងស៊ីណាត | Yin Neang Sinat | ប្រុស | ប្រធាន | ៦ |
| ២ | ហាក់ សំណាង | Hak Samnang | ប្រុស | អនុប្រធាន | ៤ |
| ៣ | ចន្នី ដាវី | Channy Davy | ស្រី | ហិរញ្ញិក | ៣ |
| ៤ | សៀង សុខចាន់ | Seang Sok Chan | ស្រី | សមាជិក | ៣ |
| ៥ | ជា ណាន់ | Chea Nan | ប្រុស | សមាជិក | ១ |
| ៦ | សួង សុវណ្ណារ័ត្ន | Suong Sovannaroath | ប្រុស | សមាជិក | ២ |
| ៧ | យ៉ែម ភារុណ | Yem Phearun | ប្រុស | សមាជិក | ២ |

ចំពោះសមាជិក ក. ចន្នី ដាវី និង អ. សៀង សុខចាន់ ដែលទទួលមាន ០៣ សំលេង ស្មើគ្នា ត្រូវបាន សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់បោះឆ្នោតអោយទាំងពីរនាក់ម្តងទៀត ដោយទទួលបានលទ្ធផល៖ ក. ចន្នី ដាវី បាន ៤ សំលេង រីឯ  សៀង សុខចាន់បាន ៣ សំលេង។ ដូចនេះ ក. ចន្នី ដាវី ទទួលតួនាទីជាហិរញ្ញិក ឯ អ. សៀង សុខចាន់ ជាសមាជិក។

## ៣.១៣. តួនាទីរបស់ ក្រុមប្រឹក្សាភិបាល

លោក ងិន សៅរ័ត្ន បានពន្យល់បន្ថែមដល់ សមាជិកក្រុមប្រឹក្សាភិបាលថ្មី អំពីតួនាទីរបស់ ក្រុមប្រឹក្សា ភិបាល ដែលត្រូវបំពេញក្នុងនាមជាក្រុមប្រឹក្សាភិបាលនៃអង្គការ ជនពិការខ្វាក់ភ្នែកខ្មែរ។

ទន្ទឹមនឹងនោះក៏មានការពិភាក្សា ពីពង្រាងលក្ខន្តិកៈជាមួយក្រុមប្រឹក្សាភិបាល ដោយសារពេលវេលាខ្លី ពង្រាងលក្ខន្តិកៈនឹងបញ្ចប់នាពេលក្រោយ។

សិក្ខាសាលាស្តីពីការគាំទ្រជនពិការខួរឆ្អឹងខ្នង និងមហាសន្និបាតលើកទី១ នៅមណ្ឌលស្តារលទ្ធភាពពលកម្មអ្នករបួសខួរឆ្អឹងខ្នងខេត្ត បាត់ដំបង ត្រូវបានបញ្ចប់នាថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ វេលាម៉ោង ១១៖៣០ ព្រឹក ប្រកបដោយបរិយាកាសរីករាយ។



## របាយការណ៍សិក្ខាសាលា ស្តីពីការគាំទ្រជនពិការខួរឆ្អឹងខ្នង និងមហាសន្និបាតលើកទី១ ផលិតនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣

| | | |
|---|---|---|
| រៀបចំដោយ<br>លោក គី សុផាន់<br>ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ<br>អង្គការជនពិការកម្ពុជា<br>អ្នកសម្របសម្រួលសិក្ខាសាលា<br>និងមហាសន្និបាត | ពិនិត្យដោយ<br>លោក ង៉ិន សៅរ័ត្ន<br>នាយកប្រតិបត្តិ<br>អង្គការជនពិការកម្ពុជា<br>អ្នកសម្របសម្រួលសិក្ខាសាលា<br>និងមហាសន្និបាត | ឯកភាពដោយ៖<br>លោក យិន នាងស៊ីណាត<br>ប្រធានក្រុមប្រឹក្សាភិបាល<br>អង្គការជនពិការខួរឆ្អឹងខ្នង |